# ការឈប់សម្រាកពីការងារ ដើម្បីទៅបោះឆ្នោត

VOTE 2022

អ្នកមានសិទ្ធិក្នុងការឈប់សម្រាកពីការងារដើម្បីទៅ បោះឆ្នោតដោយគ្មានការកាត់
ប្រាក់បៀវត្សរ៍ ការឈប់ សម្រាប់ផ្ទាល់ខ្លួន ឬពេលវេលាវិស្សមកាល។

និយោជករបស់អ្នកត្រូវទូទាត់ប្រាក់ជូនអ្នកសម្រាប់ ពេលវេលាដែលអ្នកត្រូវទៅបោះឆ្នោត ប្រសិនបើថ្ងៃ បោះឆ្នោតចំម៉ោងការងារធម្មតារបស់អ្នក។ និយោជក របស់
អ្នកមិនអាចតម្រូវឱ្យអ្នកប្រើប្រាស់ថ្ងៃឈប់សម្រាក ផ្ទាល់ខ្លួន ឬពេលវេលាវិស្សមកាល។

ចំណាយពេលវេលាដែលអ្នកត្រូវការចាំបាច់ដើម្បីទៅ បោះឆ្នោត និងទៅធ្វើការ។

និយោជករបស់អ្នកមិនអាចបដិសេធ ដាក់កំហិត ឬរំខាន ដល់សិទ្ធិនេះដោយផ្ទាល់ ឬដោយប្រយោល ឡើយ រួមទាំងការជ្រើសរើសពេលវេលារបស់អ្នកដើម្បី ទៅបោះឆ្នោតផង ដែរ។
និយោជករបស់អ្នកអាចសុំឱ្យអ្នកប្រាប់គាត់អំពីពេលវេលាដែលអ្នកត្រូវទៅ និងសុំឱ្យបុគ្គលិកជួយសម្រប សម្រួលអវត្តមានរបស់ខ្លួនដើម្បីកាត់បន្ថយការអាក់ខាន នៅកន្លែងធ្វើការ។

អ្នកមានសិទ្ធិឈប់សម្រាកពីការងារដើម្បីទៅបោះឆ្នោត នៅក្នុងគ្រប់ការបោះឆ្នោតប្រចាំរដ្ឋ និងសហព័ន្ធ និង នៅក្នុងគ្រប់ការបោះឆ្នោតក្នុងមូលដ្ឋានដែលបានកំណត់ពេលជាទៀងទាត់។

## កាលបរិច្ឆេទឆ្នាំ 2022

**ការបោះឆ្នោតបឋម**
ថ្ងៃអង្គារ៍ទី9 ខែសីហា

**ការបោះឆ្នោតសម្រាប់ពលរដ្ឋអវត្តមាន**
បោះឆ្នោតតាមសំបុត្រ ឬដោយផ្ទាល់ថ្ងៃទី23 ខែកញ្ញា រហូតដល់ថ្ងៃទី7 ខែវិច្ឆិកា

**ចុះឈ្មោះបោះឆ្នោត**
ចុះឈ្មោះជាមុននៅត្រឹមថ្ងៃ ទី18 ខែតុលា ដើម្បីសន្សំ សំចៃពេលវេលា នៅថ្ងៃ បោះឆ្នោត។

**ថ្ងៃបោះឆ្នោត**
ថ្ងៃអង្គារ៍ទី8 ខែវិច្ឆិកា

តទៅទំព័រក្រោយ...

# ការឈប់សម្រាកពីការងារ ដើម្បីទៅបោះឆ្នោត

VOTE 2022

.... តពីទំព័រមុខ

## ការដាក់ពាក្យប្តឹង

និយោជកដែលរំលោភទៅលើច្បាប់នេះគឺមានបទល្មើសមជ្ឈិម។ រាល់បណ្តឹងពីបុគ្គលិកគួរដាក់ប្តឹងទៅមេធាវី ប្រចាំក្រុង។

## បោះឆ្នោតមុនពេលកំណត់ជាមួយនឹងសន្លឹកឆ្នោតសម្រាប់ពលរដ្ឋអវត្តមាន

អ្នកអាចបោះឆ្នោតមុនពេលកំណត់ប្រសិនបើអ្នកមិន ចង់ទៅ ឬមិនអាចបោះឆ្នោតនៅថ្ងៃបោះឆ្នោត។ ដោយ ចាប់ផ្តើមពីថ្ងៃសុក្រទី21 ខែកញ្ញា អាចបោះឆ្នោត មុនពេលកំណត់ជាមួយនឹងសន្លឹកឆ្នោតសម្រាប់ពលរដ្ឋអវត្តមាននៅការិយាល័យបោះឆ្នោតក្នុងមូលដ្ឋានរបស់ អ្នក។ អ្នកក៏អាចដាក់ពាក្យស្នើសុំឱ្យបញ្ញូនសន្លឹកឆ្នោត សម្រាប់ពលរដ្ឋអវត្តមានតាមលិខិតផងដែរ។

ដើម្បីស្វែងរកការិយាល័យបោះឆ្នោតក្នុង មូលដ្ឋានរបស់អ្នក ឬដើម្បីស្នើសុំសន្លឹកឆ្នោតសម្រាប់ ពលរដ្ឋអវត្តមាន សូមចូលទៅកាន់វេបសាយត៍ mnvotes.gov។

### លិខិតសម្រាប់និយោជករបស់អ្នក

សូមចូលទៅកាន់វេបសាយត៍ *mnvotes.gov* ដើម្បី ស្វែងរកលិខិតដែលអ្នកអាចផ្តល់ជូននិយោជករបស់អ្នក ដើម្បីពន្យល់អំពីសិទ្ធិរបស់អ្នកក្នុងការឈប់សម្រាក ដើម្បីទៅបោះឆ្នោត។

ការិយាល័យលេខាធិការរដ្ឋ *Minnesota*
*mnvotes.gov • 1-877-600-VOTE*